# សេចក្ដីថ្លែងការណ៍របស់ប្រធានសន្និបាត នៃបណ្ដាប្រទេសសមាជិកអង្គការណាតូ ចំពោះការធ្វើប្រជាមតិលើរដ្ឋធម្មនុញ្ញប្រទេសទុយនេស៊ី ថ្ងៃទី២៥ ខែកក្កដា




NATO PARLIAMENTARY ASSEMBLY
ASSEMBLEE PARLEMENTAIRE DE L'OTAN

ថ្ងៃសៅរ៍ ២កើត ខែស្រាពណ៍ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២

លោកGerald E. Connonlly សមាជិកសភាតំណាងសហរដ្ឋអាមេរិក និងជាប្រធានសន្និបាតសភាអង្គការណាតូ បានចេញនូវសេចក្ដីថ្លែងការណ៍មួយដូចខាងក្រោម ដើម្បីជាប្រតិកម្មចំពោះការធ្វើប្រជាមតិលើរដ្ឋធម្មនុញ្ញ(ថ្មី)របស់សាធារណរដ្ឋទុយនេស៊ី កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២៖

"កាលពីឆ្នាំមុន លោកប្រធានាធិបតីKaïs Saïedនៃប្រទេសទុយនេស៊ី បានផ្អាកការងាររបស់ស្ថាប័នសភា ហើយបន្ទាប់មកទៀតបានរំលាយស្ថាប័នសភាចោល។ ចាប់តាំងពីនោះមក សន្និបាតសភាអង្គការណាតូ បានតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះស្ថានភាពវិវឌ្ឍក្នុងប្រទេសមួយនេះ។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការធ្វើប្រជាមតិថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២។ ខ្ញុំព្រួយបារម្ភយ៉ាងខ្លាំងថា រដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសទុយនេស៊ី នឹងនាំមកនូវការធ្លាក់ចុះថែមទៀតនៃលទ្ធិប្រជាធិបតេយ្យ ដែលកំពុងធ្លាក់ចុះស្រាប់ទៅហើយនៅក្នុងប្រទេសនេះ ដោយសារស្នាដៃរបស់លោកប្រធានាធិបតី Saïed។ លោកប្រធានាធិបតី Saïed កំពុងស្ថិតនៅលើផ្លូវ នៃការធ្លាក់ចុះបន្ថែមទៀតនូវប្រសិទ្ធភាពនៃស្ថាប័នប្រជាធិបតេយ្យ នីតិរដ្ឋ សិទ្ធិមនុស្ស សេរីភាពសំខាន់ៗ និងលទ្ធិប្រជាធិបតេយ្យ ដែលប្រជាជនទុយនេស៊ីខិតខំកសាងតាំងពីឆ្នាំ២០១១។

ក្នុងឆ្នាំ២០១៨ បានខ្ញុំធ្វើដំណើរទៅប្រទេសទុយនេស៊ី ជាមួយគណៈប្រតិភូនៃក្រុមភាពជាដៃគូ លទ្ធិប្រជាធិបតេយ្យ ដែលជាគណៈកម្មការទ្វេគណបក្សនយោបាយនៅក្នុងសភាតំណាងសហរដ្ឋអាមេរិក។ គណៈកម្មាធិការនេះ មានតួនាទីធ្វើការងារដោយផ្ទាល់ជាមួយសភាជុំវិញពិភពលោក ដើម្បីជួយគាំទ្រការអភិវឌ្ឍស្ថានប័ននីតិប្បញ្ញត្តិឱ្យមានលក្ខណៈឆ្លើយតបខ្ពស់។ នៅពេលនោះ ខ្ញុំនឹកឃើញនូវសុទិដ្ឋិនិយមដ៏ខ្លាំងក្លារបស់ប្រជាពលរដ្ឋទុយនេស៊ី ចំពោះតម្លៃនិងដំណើរនៃលទ្ធិប្រជាធិបតយ្យេ ដែលធ្លាប់មាននាពេលកន្លងមក។ ការរំលាយសភា ការព្រាងរដ្ឋធម្មនុញ្ញថ្មី និងធ្វើប្រជាមតិលើរដ្ឋធម្មនុញ្ញថ្មី គឺសុទ្ធតែធ្វើឡើងដោយខ្វះតម្លាភាព ខ្វះការចូលរួមទូលំទូលាយ និងខ្វះការពិភាក្សាជាសាធារណៈ។ គណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយជាច្រើន ក្នុងប្រទេសទុយនេស៊ី បានបង្ហាញការព្រួយបារម្ភយ៉ាងខ្លាំងរបស់ពួកគេ ចំពោះសកម្មភាពខាងលើ។ មិនដល់មួយភាគបីឡើយនៃអ្នកមានសិទ្ធិបោះឆ្នោត ដែលបាននាំគ្នាទៅបោះឆ្នោតធ្វើប្រជាមតិលើរដ្ឋធម្មនុញ្ញថ្មី កាលពីថ្ងៃទី ២៥ ខែកក្កដា។

លោកប្រធានាធិបតី Saïed ត្រូវតែកែតម្រូវឡើងវិញនូវបុព្វហេតុនៃសកម្មភាពខ្លួន កែតម្រូវដើម្បី

បំពេញបំណងប្រាថ្នារបស់ប្រជាជនទុយនេស៊ីដែលចង់បានលទ្ធិប្រជាធិបតេយ្យ ជាជាងកាច់ចង្កូតប្រទេសឱ្យធ្លាក់ក្នុងវិថីខ្មៅងងឹតនៃអត្តាធិបតេយ្យ។ ប្រសិនបើមិនដូច្នេះទេ ប្រទេសទុយនេស៊ីនឹងជួបការលំបាកខ្លាំងក្នុងការដោះស្រាយបញ្ហាប្រឈមនានា លំបាកខ្លាំងក្នុងការបំពេញបំណងប្រាថ្នារបស់ប្រជាជនទុយនេស៊ី និងលំបាកខ្លាំងក្នុងការធានាឱ្យមានសិទ្ធិជាមូលដ្ឋានចំពោះប្រជាជនទុយនេស៊ីគ្រប់រូប។

សភាដែលមានប្រសិទ្ធភាពនិងធម្មានុរូប គឺជាធាតុដ៏សំខាន់មួយក្នុងការកសាងបានឡើងវិញ នូវគោលការណ៍នៃការត្រួតពិនិត្យ និងការធ្វើឱ្យមានតុល្យភាពអំណាច(Checks and Balances) ដែលជាគោលការណ៍ដ៏សំខាន់ចាំបាច់ របស់លទ្ធិប្រជាធិបតេយ្យ។ សន្និបាតសភាអង្គការណាតូ នឹងតាមដានយ៉ាងយកចិត្តទុកដាក់ ចំពោះជំហានបន្តបន្ទាប់ទៀត ដែលអនុវត្តដោយរដ្ឋាភិបាលទុយនេស៊ី ពីពេលនេះរហូតដល់ការបោះឆ្នោតជ្រើសតាំងសមាជិកសភា ក្នុងខែធ្នូ ឆ្នាំ២០២២។ សន្និបាតសភាអង្គការណាតូ សង្ឃឹមថា ស្ថានភាពក្នុងប្រទេសទុយនេស៊ីនឹងអំណោយផលចំពោះការកើតមានសាឡើងវិញ នូវកិច្ចសហប្រតិបត្តិការសភា ជាមួយសន្និបាតសភាអង្គការណាតូ។”

គួសបញ្ជាក់ផងដែរថា សភារបស់សាធារណរដ្ឋទុយនេស៊ី ដែលមានឈ្មោះថា សន្និបាតរបស់តំណាងប្រជាជន(The Assembly of People's Representatives) បានក្លាយជាសភាសង្កេតការណ៍ នៃសន្និបាត សភាអង្គការណាតូ តាំងពីឆ្នាំ១៩៩៦។ គណៈប្រតិភូសភាប្រទេសទុយនេស៊ី បានចូលរួមជាទៀងទាត់ក្នុង សកម្មភាពរបស់សន្និបាតសភាអង្គការណាតូ ជាពិសេសសកម្មភាពការងាររបស់សន្និបាតសភាអង្គការណា តូនៅក្នុងតំបន់មេឌីទែរ៉ាណេ និងក្រុមការងារពិសេសសម្រាប់តំបន់មជ្ឈិមបូព៌ា(វេទិកាដែលសមាជិកសភា នៃប្រទេសជាសមាជិកអង្គការណាតូ និង សមាជិកសភានៃប្រទេសក្នុងតំបន់មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង ជួបពិភាក្សាគ្នាអំពីបញ្ហានយោបាយ សន្តិសុខ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ)។

សន្និបាតសភាអង្គការណាតូ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៥៥ ដើរតួនាទីជាអង្គការពិគ្រោះយោបល់អន្តរសភាសម្រាប់សម្ព័ន្ធមិត្រក្នុងតំបន់អាត្លង់ទិកខាងត្បូង។ សន្និបាតនេះមានប្រតិភូចំនួន២៦៩រូប មកពី៣០ប្រទេសជាសមាជិកអង្គការណាតូ។ក្រៅពីប្រតិភូមកពីប្រទេសជាសមាជិកអង្គការណាតូ សន្និបាត ក៏មានប្រតិភូជាច្រើនក្រុមទៀតផងដែរ(សូមមើលរូបភាព ក្នុងទំព័របន្ទាប់) ដែលចូលរួមក្នុងសកម្មភាព ការងារផ្សេងៗរបស់សន្និបាត។ សន្និបាតសភាអង្គការណាតូ ត្រូវបានដឹកនាំដោយគណៈកម្មាធិការ អចិន្ត្រៃយ៍ (Standing committee) ដែលមានប្រធាន១រូប អនុប្រធាន៥រូប ប្រធានគណៈប្រតិភូនៃប្រទេសជា សមាជិកអង្គការណាតូ និងអគ្គលេខាធិការ១រូប។ សន្និបាតសភាអង្គការណាតូ បានបង្កើត គណៈកម្មាធិការ ក្រុមការងារពិសេស និងក្រុមប្រឹក្សា សរុបចំនួន៩ទៀត ដើម្បីអនុវត្តការងាររបស់ខ្លួន៕

*ព័ត៌មានអង្គការសភាអន្តរជាតិ ៣០-០៧-២២- មាស តូនី*

ប្រែសម្រួលពី (1)https://www.nato-pa.int/news/nato-pa-presidents-statement-tunisias-25-july-constitutional-referendum

(2)https://www.nato-pa.int/download-file?filename=/sites/default/files/2022-07/ASSEMBLY%20LEAFLET%20-%20JUNE%202022%20.pdf

NATO PARLIAMENTARY ASSEMBLY
ASSEMBLEE PARLEMENTAIRE DE L'OTAN

| Member States | Delegates | |
|---|---|---|
| United States | 36 | |
| France | 18 | |
| Germany | 18 | |
| Italy | 18 | |
| Türkiye | 18 | |
| United Kingdom | 18 | |
| Canada | 12 | |
| Poland | 12 | |
| Spain | 12 | |
| Romania | 10 | |
| Belgium | 7 | |
| Czech Republic | 7 | |
| Greece | 7 | |
| Hungary | 7 | |
| Netherlands | 7 | |
| Portugal | 7 | |
| Bulgaria | 6 | |
| Denmark | 5 | |
| Norway | 5 | |
| Slovakia | 5 | |
| Croatia | 5 | |
| Lithuania | 4 | |
| Albania | 4 | |
| Estonia | 3 | |
| Iceland | 3 | |
| Latvia | 3 | |
| Luxembourg | 3 | |
| Montenegro | 3 | |
| North Macedonia | 3 | |
| Slovenia | 3 | |
| **30** | **269** | |

| Associate Delegations | | |
|---|---|---|
| Ukraine | 8 | |
| Austria | 5 | |
| Azerbaijan | 5 | |
| Serbia | 5 | |
| Sweden | 5 | |
| Switzerland | 5 | |
| Finland | 4 | |
| Georgia | 4 | |
| Armenia | 3 | |
| Bosnia and Herzegovina | 3 | |
| Republic of Moldova | 3 | |
| **11** | **50** | |

| European Parliament Delegation | | |
|---|---|---|
| | 10 | |

| Regional Partner and Mediterranean Associate Member Delegations | | |
|---|---|---|
| Algeria | 3 | |
| Morocco | 3 | |
| Israel | 3 | |
| Jordan | 3 | |
| **4** | **12** | |

| Parliamentary Observer Delegations | | |
|---|---|---|
| Assembly of Kosovo | 2 | |
| Australia | 2 | |
| Egypt | 2 | |
| Japan | 2 | |
| Kazakhstan | 2 | |
| Palestinian National Council | 2 | |
| Republic of Korea | 2 | |
| Tunisia | 2 | |
| **8** | **16** | |

| Inter-Parliamentary Assembly Delegations | | |
|---|---|---|
| OSCE PA | 2 | |
| PACE | 2 | |
| **2** | **4** | |

## COMMITTEES, SUB-COMMITTEES & WORKING GROUPS

**Committee on Democracy and Security (CDS)**
Sub-Committee on Resilience and Civil Security (CDSRCS)

**Defence and Security Committee (DSC)**
Sub-Committee on Future Security and Defence Capabilities (DSCFC)
Sub-Committee on Transatlantic Defence and Security Cooperation (DSCTC)

**Economics and Security Committee (ESC)**
Sub-Committee on Transition and Development (ESCTD)
Sub-Committee on Transatlantic Economic Relations (ESCTER)

**Political Committee (PC)**
Sub-Committee on NATO Partnerships (PCNP)
Sub-Committee on Transatlantic Relations (PCTR)

**Science and Technology Committee (STC)**
Sub-Committee on Technology Trends and Security (STCTTS)

**Mediterranean and Middle East Special Group (GSM)**

**Ukraine-NATO Inter-Parliamentary Council (UNIC)**

**Georgia-NATO Inter-Parliamentary Council (GNIC)**

**NATO-Russia Parliamentary Committee (NRPC)**
(Discontinued as of April 2014)

# NATO PA President’s Statement on Tunisia’s 25 July Constitutional Referendum

The President of the NATO Parliamentary Assembly (NATO PA), Gerald E. Connolly (United States), issued the following statement in reaction to Tunisia’s constitutional referendum held on 25 July.

“A year ago, Tunisian President Kaïs Saïed suspended parliament, which he later dissolved.

The Assembly has since followed developments in Tunisia closely.

I am gravely concerned that the referendum of 25 July and the new constitution will codify the democratic backsliding that has already taken place in Tunisia at the hands of President Kaïs Saïed.

President Saïed is on track to further erode existing democratic institutions, the rule of law, human rights, essential freedoms and the democracy Tunisians have been trying to build since 2011.

When I travelled to Tunisia in 2018 with a delegation from the United States House Democracy Partnership, a bipartisan commission of the US House of Representatives that works directly with parliaments around the world to support the development of responsive legislative institutions, I recall the palpable optimism of the Tunisian people for institutional democratic values and processes.

From the dissolution of parliament to the constitutional drafting process to the referendum itself, transparency, inclusive participation and public dialogue has been lacking. Many Tunisian political parties, civil society organizations and media outlets have noted their serious concerns throughout. Less than one-third of eligible voters ended up casting a ballot on the referendum.

President Saïed must correct his course to deliver on the democratic ambitions of the Tunisian people instead of steering Tunisia towards the dark path of autocracy. Otherwise, it will become exceedingly difficult to address Tunisia’s challenges, to meet the expectations of the Tunisian people and to guarantee the fundamental rights of all Tunisians.

A functioning and legitimate parliament is an essential element to reestablishing the checks and balances necessary for a working democracy. The Assembly will closely follow the next steps taken by the government in Tunis ahead of the December parliamentary elections, in the hope that conditions allow for renewed interparliamentary cooperation with the NATO PA.”

The country’s Parliament, the Assembly of People's Representatives, has been a Parliamentary Observer in the NATO PA since 1996. Tunisia’s parliamentary delegation

has regularly participated in Assembly activities, in particular in the work of the NATO PA Mediterranean and Middle East Special Group (GSM), a forum where parliamentarians from NATO countries and the Middle East and North Africa discuss political and security issues and pursue enhanced cooperation.